# ការប្រើស្រោមលឹង

១. ចូរអ្នកពិគ្រោះជាមួយគូស្នេហាជាមុន អំពីការប្រើស្រោមលឹង។

២. ចូរពិនិត្យនៅលើកញ្ចប់ មើលថ្ងៃខែដែលស្រោមលឹងត្រូវខូច ប្រើមិនបាន។

៣. ចូរសាកល្បងប្រើស្រោមលឹងជាមុន។ ចូរ សាកម៉ាកផ្សេងៗ ជ្រើសរើសរកទំហំអោយបានត្រឹមត្រូវ។

៤. ចូរពាក់ស្រោមលឹង មុននឹងសេពកាម។ ប្រយ័ត្នកុំអោយឆ្កូតដាច់រហែក ដោយសារចិញ្ចៀន រឺក៏ក្រចកដៃ។

៥. ចូរច្បូតស្រោមអោយទៅដល់គល់លឹង។

៦. ចូរកាន់ទប់គល់ស្រោម នៅពេលដែលអ្នកដកលឹងចេញពីយោនី ។

៧. ចូរប្រើធាតុរំអិលដែលមានជាតិទឹក ដូចជាម៉ាក ឃីចេល្លី រឺក៏វេតស្តារ។ ជៀសវាងកុំប្រើធាតុរំអិលដែលមានជាតិប្រេង ដូចជាខ្លាញ់វ៉ាសាលីន រឺក៏ប្រេងទារក(ជាតិប្រេងនេះ ធ្វើអោយខូចស្រោមកៅស៊ូ) ។

៨. ចូរចោលស្រោមលឹងក្នុងធុងសំរាម កុំចោលក្នុងបង្គន់។



*គំនូរនេះផ្តល់ដោយ គណកម្មការជាតិទីព្រឹក្សា ខាងជំងឺអេដ។*

## NSW SEXUAL HEALTH SERVICES

**Providing free and confidential sexual health care.**

| | |
|---|---|
| Albury | Ph: (02) 6058 1831 |
| Balranald | Ph: (03) 5027 2345 |
| Bourke | Ph: (02) 68722145 |
| Broken Hill | Ph: (08) 8088 5800 |
| Canterbury | Ph: (02) 9718 7655 |
| Coffs Harbour | Ph: (02) 6659 1916 |
| Dubbo | Ph: (02) 6885 1700 |
| Forster | Ph: (02) 6555 6822 |
| Gosford | Ph: (02) 4320 2114 |
| Goulburn | Ph: (02) 4827 3470 |
| Katoomba | Ph: (02) 4780 6060 |
| Kings Cross | Ph: (02) 9360 2766 |
| Kogarah | Ph: (02) 9350 2742 |
| Lightning Ridge | Ph: (02) 68291022 |
| Lismore | Ph: (02) 6620 2980 |
| Liverpool | Ph: (02) 9827 8022 |
| Manly | Ph: (02) 9977 3288 |
| Marrickville | Ph: (02) 9560 3057 |
| Newcastle | Ph: (02) 4923 6909 |
| Nowra | Ph: (02) 4423 9353 |
| Orange | Ph: (02) 6361 9906 |
| Parramatta | Ph: (02) 9843 3124 |
| Penrith | Ph: (02) 4724 2507 |
| Port Kembla | Ph: (02) 4276 2399 |
| Richmond | Ph: (02) 4578 1622 |
| St Leonards | Ph: (02) 9926 7414 |
| Sydney City | Ph: (02) 9382 7440 |
| Tamworth | Ph: (02) 6766 3095 |
| Taree | Ph: (02) 6551 1315 |
| Wagga Wagga | Ph: (02) 6938 6492 |

Khmer

# មេរោគវ៉ាយរ៏ស ហិបាតៃតិសអេ

## Hepatitis A Virus

SYDNEY SEXUAL HEALTH CENTRE

និង ផ្នែកសិក្សានៃវេជ្ជសាស្ត្រខាងសុខភាពនៃការសេពកាម សាកលវិទ្យាល័យស៊ីដនី/សាកលវិទ្យាល័យញូសោធវេល

November 1994

## អ្វីទៅដែលបង្ករអោយមានជំងឺនេះ?

ហិបាតៃតិសអេ អាចធ្វើអោយហើមរលាកថ្លើម (រឺក៏ជំងឺថ្លើម) ដែល បណ្តាលមកអំពីវ៉ាយរឺសហិបាតៃតិសអេ។

## តើគេអាចទទួលកើតជំងឺនេះតាមបែបណា?

វ៉ាយរឺសនេះឆ្លង នៅពេលដែលទឹកសំអុយ(ពីពោះវៀន)ចេញពីអ្នកជំងឺ ចូលទៅក្នុងមាត់មនុស្សម្នាក់ទៀត។

ការឆ្លង កើតឡើងតាមបែបខាងក្រោមនេះ :

- ទឹក រឺក៏អាហារដែលមិនស្អាត មានមេរោគកកើតទៅហើយ។
- ការសេពកាមតាមរន្ធគូថ រឺតាមជាយរង្វង់រន្ធគូថ។ សូមកត់សំគាល់ថាស្រោមលឹងពុំការពារប្រឆាំងនឹងហិបាតៃតិសអេនេះបានទេ។
- ការមិនលាងដៃអោយស្អាត ក្រោយពេលដែលអាចប៉ះពាល់នឹង ទឹកសំអុយពោះវៀននេះ។

## តើរោគសញ្ញាមានអ្វីខ្លះ?

មនុស្សចាស់ភាគច្រើនដែលកើតរោគនេះ មានអាការរោគដែលរាប់តាំងពីគ្មានអ្វីសោះ ដល់ជំងឺផ្តាសសាយបន្តិចបន្តួច រហូតដល់ការក្អួតចង្អោរ ចុកពោះ និងកើតខាន់លឿង (ស្បែកឡើងពណ៌លឿងហើយស្លាំង)។

អាការរោគទាំងនេះនឹងរំងាប់ ក្នុងរយះពេលពីរាប់អាទិត្យ ទៅរាប់ខែ ហើយអ្នកជំងឺនេះនឹងឡើងស៊ាំជាមួយរោគនេះ។ ហិបាតៃតិសអេក៏រធ្វើអោយអ្នកជំងឺស្លាប់ណាស់។

## ពេលណាដែលអ្នកជំងឺអាចចំលងរោគ?

អ្នកជំងឺអាចចំលងមេរោគចាប់តាំងពីពេលពីអាទិត្យមុនគេបញ្ចេញរោគសញ្ញា រហូតដល់មួយអាទិត្យក្រោយពេលដែលគេកើតខាន់លឿង គឺសារុបទៅ ក្នុងរយះពេលប្រមាណជាបីទៅបួនអាទិត្យ ។ ក្រោយពីកើត ហិបាតៃតិសអេយ៉ាងខ្លាំងមក អ្នកជំងឺភាគច្រើននឹងឡើងស៊ាំនឹងរោគនេះ។ ការនេះមានន័យថា អីឡូវគេមានធាតុប្រឆាំងនឹងមេរោគហិបាតៃតិសអេនេះមួយជីវិត ហើយគេពុំអាចនឹងចំលងរោគនេះទៀតកើតឡើយ។

## តើអ្នកកើតរោគហិបាតៃតិសអេនេះ គួរធ្វើអ្វីខ្លះ ដើម្បីកុំអោយឆ្លងដល់អ្នកអែទៀត?

លាងដៃជាមួយសាប៊ូអោយស្អាត ក្រោយពេលបត់ជើងរួច ។
កុំរៀបចំធ្វើម្ហូបអាហារ រឺទឹកអោយគេអាស្រ័យ ។
កុំចូលបរិភោគអាហាររួមជាមួយគេអែទៀត ។
កុំប្រើប្រាស់កំរាលពូក កន្សែង រឺក៏សមស្លាបព្រាលាយឡំជាមួយអ្នកអែទៀត។

**កំណត់ចំណាំ** : ក្រោយពីលាងសំអាតចានសមស្លាបព្រា និងកំរាលពូករួចហើយ អ្នកអែទៀតអាចប្រើប្រាស់របស់ទាំងនោះបាន។ ចូរជៀសវាងការសេពកាមតាមរន្ធគូថមួយរយះពេល ទំរាំជាសះស្បើយ។ អ្នកដែលមានរបរចិញ្ចឹមជីវិតទាក់ទងនឹងការប៉ះពាល់ម្ហូបអាហារ អ្នកថែរក្សាក្មេង រឺក៏អ្នកធ្វើការខាងកិច្ចបំរើសុខភាព គួរតែប្រាប់គ្រូពេទ្យអំពីរបរគេនេះហើយកុំត្រឡប់ចូលធ្វើការមុនពេលពេទ្យអនុញ្ញាត។

## តើគេអាចចំលងមេរោគហិបាតៃតិសអេនេះ ទៅអ្នកនៅផ្ទះជាមួយគ្នាដែររឺទេ?

គេអាចចំលងមេរោគហិបាតៃតិសអេទៅអ្នកដែលនៅផ្ទះជាមួយគ្នាបាន។ អ្នកដែលមានការទាក់ទងប្រាស្រ័យគ្នាបែបនេះ គួរតែទៅចាក់ថ្នាំអោយស៊ាំនឹងវ៉ាយរឺសហិបាតៃតិសអេនេះ (ហ្គាម៉ាគ្លូបូលិន gammaglobulin ដែលអាចការពារបានបីខែ)។ ថ្នាំហ្គាម៉ាគ្លូបូលិននេះមាននៅតាមមន្ទីព្យាបាលរោគ គ្រូពេទ្យដំបន់និង មន្ទីសុខភាពខាងការសេពកាមនានា ។

## តើគេមានថ្នាំចាក់ណាដែលអាចបង្ការហិបាតៃតិសអេនេះអោយបានយូរអង្វែងដែររឺទេ?

ក្នុងឆ្នាំ១៩៩៣/៩៤ អូស្ត្រាលីនឹងមានថ្នាំចាក់ដែលមានប្រសិទ្ធភាពយូរ ។ ថ្វីបើថ្នាំនេះថ្លៃ គេនឹងស្នើថ្នាំនេះ សំរាប់បុរសណាដែលសេពកាមជាមួយប្រុសៗ អ្នកធ្វើការតាមលូសំអុយ ជាងបំពង់ទឹក ហើយនិងអ្នកទាំង ឡាយណា ដែលធ្វើដំណើរទៅដំបន់ដែលមានទឹកមិនស្អាត។

